# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីសម្រេចកែសម្រួលលើកទី៣
# លើឯកសារអាជ្ញាប័ណ្ណ លេខ ០១៤ ឯអ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០២
# ដើម្បីប្តូរឈ្មោះពីក្រុមហ៊ុន ឌូធី ហ្វ្រី សប់ ទៅក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប
# អាជ្ញាធរអគ្គិសនីកម្ពុជា

- អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១
- យោងឯកសារអាជ្ញាប័ណ្ណលេខ០១៤ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឱ្យក្រុមហ៊ុន ឌូធី ហ្វ្រី សប់ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០២
- យោងពាក្យស្នើសុំប្តូរនាមករណ៍ក្រុមហ៊ុន ឌូធី ហ្វ្រី សប់ ទៅជាក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប លេខ១១៨/០៧ ឧហស ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៧
- យោងវិញ្ញាបនប័ត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប លេខ ២០២៥ ពណ.នគក ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៧
- យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៧ ដល់ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៧
- យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី ១២០ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៨

## សម្រេច

**ប្រការ១**

កែសម្រួលឯកសារអាជ្ញាប័ណ្ណលេខ ០១៤ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជា ចេញឱ្យ**ក្រុមហ៊ុន ឌូធី ហ្វ្រី សប់** ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០២ ដោយ ប្តូរឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណពី**ក្រុមហ៊ុន ឌូធី ហ្វ្រី សប់** មកជា**ក្រុមហ៊ុន អិល .វ៉ាយ.ភី គ្រុប** (បន្ទាប់ពីនេះហៅថា "**អ្នកកាន់អាជ្ញាប័ណ្ណ**") មានទីស្នាក់ការនៅ ភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង និងដែលមានវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ ២០២៥ ពណ.នគក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៧ ស្ថិតនៅក្រោមបទបញ្ញត្តិនៃក្រមពាណិជ្ជកម្ម និងរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ធ្វើសេវាកម្មចែកចាយអគ្គិសនីនៅ (១)ទីរួមខេត្តកោះកុង, (២)ទីប្រជុំជនអូរស្មាច់ ឃុំអូរស្មាច់ ស្រុកសំរោង ខេត្តឧត្តរមានជ័យ និង(៣) ទីរួមខេត្តឧត្តរមានជ័យ និងតំបន់ខ្លះស្ថិតតាមបណ្តោយផ្លូវលេខ ៦៨ ភ្ជាប់ពីទីប្រជុំជនអូរស្មាច់ មកទីរួមខេត្តឧត្តរមានជ័យ ។

**ប្រការ២**

ឧបសម្ព័ន្ធទី៤ “ម្ចាស់កម្មសិទ្ធិនៃអ្នកកាន់អាជ្ញាប័ណ្ណ” នៃឯកសារអាជ្ញាប័ណ្ណ លេខ ១៥០ ឯអ ត្រូវជំនួស ដោយឧបសម្ព័ន្ធទី៤ កែសម្រួលថ្មី ដែលមានភ្ជាប់មកជាមួយ ។

**ប្រការ៣**

សេចក្តីសម្រេចនេះ ត្រូវក្លាយជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ០១៤ ឯអ ។

**ប្រការ៤**

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ០១៤ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។

**ប្រការ៥**

សេចក្តីសម្រេចនេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៦**

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែង ដែលឯកសារអាជ្ញាប័ណ្ណលេខ ០១៤ ឯអ បានតម្កល់ទុកពីមុនដើម្បីឱ្យ ឯកសារអាជ្ញាប័ណ្ណលេខ ០១៤ ឯអ ដែលតម្កល់មានការកែសម្រួលជាថ្មីស្រប តាមសេចក្តីសម្រេចនេះ ។

ភ្នំពេញ, ថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៨

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

# ឧបសម្ព័ន្ធទី៤
# ម្ចាស់កម្មសិទ្ធិនៃអ្នកកាន់អាជ្ញាប័ណ្ណ

១- អ្នកកាន់អាជ្ញាប័ណ្ណរួមមានម្ចាស់កម្មសិទ្ធិ ដែលបានចុះបញ្ជីក្នុង **ក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប** ដែលម្ចាស់ភាគហ៊ុនមានសមាសភាពដូចខាង ក្រោម៖

(ក) លោកស្រី **គីម ហ៊ាង** មានចំនួន ៧០ ភាគហ៊ុន ពីលេខ ០១ ដល់ ៧០

(ខ) កញ្ញា **លី អាផណា** មានចំនួន ៣០ ភាគហ៊ុន ពីលេខ ៧១ ដល់ ១០០

២- យោងតាមមាត្រា ៤៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ម្ចាស់កម្មសិទ្ធិ ដែលបានចុះបញ្ជីដូចខាងលើ ពុំអាចមានភាគហ៊ុន ឬមានផលប្រយោជន៍ហិរញ្ញវត្ថុផ្ទាល់ជាមួយអ្នកកាន់អាជ្ញាប័ណ្ណផ្សេងទៀត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍ពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ ក្នុងករណីជាក់លាក់ណាមួយ ដើម្បីជាផលប្រយោជន៍សាធារណៈអាជ្ញាធរអគ្គិសនីកម្ពុជាអាចចេញសេចក្តីសម្រេចអនុញ្ញាតឱ្យបាន ។

លក្ខខណ្ឌរបស់អាជ្ញាប័ណ្ណនេះមានខ្លឹមសារដូចអាជ្ញាប័ណ្ណលេខ ០១៥.ឯអ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០២ ។ប្រសិនបើចង់ពិនិត្យមើលខ្លឹមសារ សូមពិនិត្យមើលផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះ ។